KB PRASAC Bank

ធនាគារ ខេប៊ីប្រាសាក់ ម.ក

លក្ខខណ្ឌទូទៅនៃការប្រើប្រាស់ផលិតផល និង សេវាកម្មរបស់ ធនាគារ ខេប៊ីប្រាសាក់ ម.ក

General Terms and Conditions of Using Products and Services of KB PRASAC Bank Plc.

បោះពុម្ពលើកទី ៣

អារម្ភកថា

I. សេចក្តីផ្តើម 1
II. និយមន័យនៃពាក្យគន្លឹះ 1
III. លក្ខខណ្ឌទូទៅនៃការប្រើប្រាស់ផលិតផល និងសេវាកម្មរបស់ខេប៊ីប្រាសាក់ 3
1. ប្រភេទគណនី 3
2. ការបើកគណនី 3
3. គណនីរួម 4
4. គណនីនីតិបុគ្គល 4
5. គណនីគ្មានប្រតិបត្តិការ 4
.6 ការផ្តល់ព័ត៌មានរបស់អតិថិជន 4
7. ការស្នើសុំកែប្រែព័ត៌មាន និងការជូនដំណឹងពីអតិថិជន 5
8. ការដាក់ប្រាក់បញ្ញើ 5
9. ការដក ឬ ផ្ទេរប្រាក់បញ្ញើ 6
10. ឥណទានវិបារូបន៍ (ការដកប្រាក់ដែលធ្វើឱ្យសមតុល្យក្រោមសូន្យ) 6
11. ការប្រើប្រាស់មូលប្បទានប័ត្រ 7
12. សេវាធនាគារអន្តរជាតិ 8
13. ការបញ្ជាទូទាត់ 8
14. ការបង្កាំងគណនី ឬ សមតុល្យគណនី 9
15. ការដោះបង្កាំងគណនី ឬ សមតុល្យគណនី 9
16. កម្រៃសេវាកម្ម 9
17. អត្រាការប្រាក់លើប្រាក់បញ្ញើ 9
18. ការកែប្រែកម្រៃសេវា អត្រាការប្រាក់ ទំហំកំណត់ លក្ខខណ្ឌផ្សេងៗ និងការជូនដំណឹងទៅអតិថិជន 10
19. ពន្ធកាត់ទុក (ពន្ធលើការប្រាក់) 10
20. ទំហំទឹកប្រាក់បញ្ញើ 10
21. ប្រភេទរូបិយប័ណ្ណ 11
22. អត្រាប្តូរប្រាក់ 11
23. ការស្នើសុំបិទគណនី 11
24. ឯកសារគណនី (សៀវភៅគណនីសន្សំ/វិញ្ញាបនបត្រប្រាក់បញ្ញើមានកាលកំណត់/ប័ណ្ណព័ត៌មានគណនី) 11
25. របាយការណ៍គណនី 12
26. សិទ្ធិក្នុងការទូទាត់ 12
27. ការរំខានដល់សេវាកម្ម និងប្រធានសក្តិ 13
28. ការរក្សាព័ត៌មានអតិថិជនជាការសម្ងាត់ 13
29. ការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងបទឧក្រិដ្ឋផ្សេងៗ 13
30. ច្បាប់អនុវត្ត 14

I. សេចក្តីផ្តើម

លក្ខខណ្ឌទូទៅនៃការប្រើប្រាស់ផលិតផល និងសេវាកម្មជាមួយ **ធនាគារ ខេប៊ីប្រាសាក់ ម.ក** តទៅហៅថា **«ខេប៊ីប្រាសាក់»** ត្រូវបានបង្កើតឡើងដើម្បីជួយដល់អតិថិជនទាំងអស់របស់ខេប៊ីប្រាសាក់ តទៅហៅថា «**អតិថិជន**» ក្នុងការស្វែងយល់អំពីលក្ខខណ្ឌទូទៅនៃការប្រើប្រាស់ផលិតផល និង/ឬ សេវាកម្មនានារបស់ខេប៊ីប្រាសាក់ តទៅហៅថា «**លក្ខខណ្ឌទូទៅ**» មុនពេលសម្រេចចិត្តជ្រើសរើស និងប្រើប្រាស់សេវាកម្មណាមួយជាមួយខេប៊ីប្រាសាក់។

ចាប់ពីថ្ងៃដែលអតិថិជនបានបំពេញពាក្យស្នើសុំប្រើប្រាស់ផលិតផល និង/ឬ សេវាកម្មរបស់ខេប៊ីប្រាសាក់ និង/ឬ ក្នុងករណីដែលអតិថិជនធ្វើការបញ្ជូនមកខេប៊ីប្រាសាក់ឱ្យធ្វើប្រតិបត្តិការ និង/ឬ សេវាអ្វីមួយដោយមិនបានប្រើប្រាស់ទម្រង់ ឬ ឯកសាររបស់ខេប៊ីប្រាសាក់ក៏ដោយ អតិថិជនត្រូវបានសន្មតថា បានអាន និងយល់ព្រមអនុវត្តតាមលក្ខខណ្ឌនានាដែលមានចែងនៅក្នុងលក្ខខណ្ឌទូទៅនេះ និងលក្ខខណ្ឌលម្អិតផ្សេងៗទៀតពាក់ព័ន្ធនឹងការប្រើប្រាស់ផលិតផល និង/ឬ សេវាកម្មនីមួយៗរបស់ខេប៊ីប្រាសាក់។

ករណីអតិថិជនមានភាពមិនច្បាស់លាស់លើចំណុចណាមួយដែលបានចែងក្នុងលក្ខខណ្ឌទូទៅនេះ អតិថិជនអាចស្វែងរកការពន្យល់បន្ថែមពីបុគ្គលិកខេប៊ីប្រាសាក់ដោយផ្ទាល់នៅគ្រប់សាខាខេប៊ីប្រាសាក់ទាំងអស់ ឬ តាមរយៈទូរស័ព្ទទៅកាន់លេខ 023/086 999 911 បានគ្រប់ពេលវេលា។

II. និយមន័យនៃពាក្យគន្លឹះ

- ខេប៊ីប្រាសាក់ ៖ សំដៅលើ ធនាគារ ខេប៊ីប្រាសាក់ ម.ក
- អតិថិជន ៖ សំដៅលើបុគ្គលជាម្ចាស់គណនី ឬ មិនមានគណនីជាមួយខេប៊ីប្រាសាក់ដែលបានប្រើប្រាស់សេវាណាមួយរបស់ខេប៊ីប្រាសាក់
- គណនី ៖ សំដៅលើគ្រប់ប្រភេទគណនីប្រាក់បញ្ញើសន្សំ និង/ឬ គណនីចរន្ត និង/ឬ គណនីបញ្ញើមានកាលកំណត់ ទាំងឡាយដែលអតិថិជនប្រើប្រាស់ជាមួយខេប៊ីប្រាសាក់
- គណនីរួម ៖ សំដៅលើគណនីទាំងឡាយណាដែលមានសមាជិករួមគណនីចាប់ពី ០២ នាក់ឡើងទៅ
- ម្ចាស់គណនី ៖ សំដៅលើរូបវន្តបុគ្គល ឬ អង្គភាពទាំងឡាយណា ដែលបានឈរឈ្មោះបើកគណនីជាមួយខេប៊ីប្រាសាក់
- អ្នករួមគណនី ៖ សំដៅលើអតិថិជនជាម្ចាស់គណនីដែលឈរឈ្មោះជាសមាជិករួមគណនី
- ប្រាក់បញ្ញើ ៖ សំដៅលើទឹកប្រាក់ដែលអតិថិជនបានដាក់បញ្ញើជាមួយខេប៊ីប្រាសាក់
- របាយការណ៍គណនី ៖ សំដៅលើកំណត់ត្រាប្រតិបត្តិការចេញ ឬ ចូលទាំងឡាយនៅក្នុងគណនី
- ឯកសារគណនី ៖ សំដៅលើសៀវភៅគណនីសន្សំ សម្រាប់គណនីសន្សំ និង/ឬ វិញ្ញាបនបត្រសម្រាប់គណនីបញ្ញើមានកាលកំណត់ ឬ ប័ណ្ណព័ត៌មានគណនីជាដើម។ល។

- គណនីចរន្ត ៖ គឺជាគណនីមួយប្រភេទប្រើប្រាស់សម្រាប់ការទូទាត់ ដោយប្រើប្រាស់មូលប្បទានប័ត្រសម្រាប់ការទូទាត់ផ្សេងៗ។
- មូលប្បទានប័ត្រ ៖ សំដៅដល់បញ្ជាជាលាយលក្ខណ៍អក្សរដោយឥតលក្ខខណ្ឌឱ្យទៅធនាគារ និងចុះហត្ថលេខាដោយបុគ្គលជាអ្នកចេញបញ្ជា តម្រូវឱ្យធនាគារទូទាត់សងចំនួនប្រាក់ជាកំណត់មួយឱ្យទៅ ឬ តាមបញ្ជាបុគ្គលមួយទៀត ឬ អ្នកកាន់។
- មូលប្បទានប័ត្រធនាគារិក ៖ សំដៅដល់មូលប្បទានប័ត្រចេញផ្សាយដោយធនាគារ និងចុះហត្ថលេខាដោយថ្នាក់គ្រប់គ្រងរបស់ធនាគារ តម្រូវឱ្យធនាគារទូទាត់សងចំនួនប្រាក់ជាកំណត់មួយឱ្យទៅ បុគ្គលអ្នកទទួលផលណាមួយ តាមការស្នើសុំទិញរបស់អតិថិជន ឬ ធនាគារចេញមូលប្បទានប័ត្រធនាគារិកនេះដើម្បីទូទាត់កាតព្វកិច្ច ឬ ចំណាយផ្សេងៗរបស់ធនាគារខ្លួនឯងផ្ទាល់។
- សៀវភៅមូលប្បទានប័ត្រ ៖ សំដៅដល់មូលប្បទានប័ត្រជាច្រើនសន្លឹក ចងក្រងធ្វើជាសៀវភៅមូលប្បទានប័ត្រមួយក្បាល។
- ការចេញផ្សាយ ៖ សំដៅដល់ការសរសេរ ចុះហត្ថលេខា និងប្រគល់មូលប្បទានប័ត្រ ដើម្បីជាការទូទាត់សងប្រាក់ទៅកាន់ដៃគូរអាជីវកម្ម ឬ ភាគីណាមួយ។
- បហារ័ក ៖ សំដៅដល់បុគ្គលដែលចេញបញ្ជាឱ្យទូទាត់សងមូលប្បទានប័ត្រ (ម្ចាស់គណនី ដែលជាអ្នកចេញផ្សាយមូលប្បទានប័ត្រ)។
- ខេអេចឃ្យូអរកូត ៖ គឺជាឃ្យូអរកូតស្តង់ដាមួយដែលផ្តួចផ្តើម និងដឹកនាំគម្រោងដោយ ធនាគារជាតិ នៃ កម្ពុជា ដើម្បីអនុញ្ញាតឱ្យអតិថិជនអាចធ្វើការទូទាត់ទំនិញ និងសេវាឆ្លងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលបានដាក់ឱ្យប្រើប្រាស់ KHQR Code បានយ៉ាងងាយស្រួល ឆាប់រហ័ស និងសុវត្ថិភាពខ្ពស់។
- ឯកសារបញ្ជាក់អត្តសញ្ញាណ ៖ សំដៅលើឯកសារផ្លូវច្បាប់ទាំងឡាយ ដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់បុគ្គលណាម្នាក់ដែលទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ចដូចជា៖ អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន សំបុត្រកំណើត និង/ឬ លិខិតបញ្ជាក់ផ្សេងៗ ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។
- សេវាខេប៊ីប្រាសាក់ឧបភោគ ៖ គឺជាសេវាកម្មមួយប្រភេទ ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់ធ្វើប្រតិបត្តិការលើគណនីរបស់ខ្លួន បានដោយសុវត្ថិភាព នៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា (24/7) តាមរយៈកុំព្យូទ័រ ឬ ឧបករណ៍ (Tablet) ផ្សេងៗ ដែលបានភ្ជាប់ប្រព័ន្ធអ៊ីនធឺណែតដោយមិនចាំបាច់មកកាន់ការិយាល័យខេប៊ីប្រាសាក់ឡើយ។

- កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ៖ គឺជាសេវាកម្មមួយប្រភេទ ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់ធ្វើប្រតិបត្តិការលើគណនីរបស់ខ្លួនបានដោយសុវត្ថិភាព នៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា (24/7) តាមរយៈទូរស័ព្ទដៃវៃឆ្លាត ដែលបានភ្ជាប់ប្រព័ន្ធអ៊ីនធឺណែត ដោយមិនចាំបាច់មកកាន់សាខាខេប៊ីប្រាសាក់ឡើយ។

III. លក្ខខណ្ឌទូទៅនៃការប្រើប្រាស់ផលិតផល និងសេវាកម្មរបស់ខេប៊ីប្រាសាក់

1. ប្រភេទគណនី

អតិថិជនអាចជ្រើសរើសបើកគណនីនៅខេប៊ីប្រាសាក់ទៅតាមប្រភេទគណនីដូចខាងក្រោម៖

1) គណនីបញ្ញើសន្សំ

- គណនីសន្សំ
- គណនីចម្រើនគ្មានកាលកំណត់
- គណនីចម្រើនតាមលំដាប់
- គណនីបើកប្រាក់បៀវត្ស
- គណនីឌីជីថល
- គណនីគ្រឹះស្ថានហិរញ្ញវត្ថុ
- គណនីសន្សំពាណិជ្ជករ និងផ្សេងៗ។

2) គណនីបញ្ញើមានកាលកំណត់

- គណនីបញ្ញើមានកាលកំណត់ (ប្រភេទ ចម្រើនការប្រាក់ចុងគ្រា និងចម្រើនការប្រាក់ប្រចាំខែ)
- គណនីបញ្ញើមានកាលកំណត់គ្រឹះស្ថានហិរញ្ញវត្ថុ (ប្រភេទ ចម្រើនការប្រាក់ចុងគ្រា និងចម្រើនការប្រាក់ប្រចាំខែ)
- គណនីសន្សំតាមផែនការ
- គណនីកូនចម្រើន
- គណនីសន្សំនិយោជិត និងផ្សេងៗ។

3) គណនីចរន្ត

- គណនីចរន្ត
- គណនីចរន្តព្រីមៀម និងផ្សេងៗ។

2. ការបើកគណនី

2.1. រាល់ពេលស្នើសុំបើកគណនីជាមួយខេប៊ីប្រាសាក់ អតិថិជនត្រូវបំពេញទម្រង់ពាក្យស្នើសុំបើកគណនីផ្តល់គំរូហត្ថលេខា ឬ ស្នាមមេដៃ ឯកសារបញ្ជាក់អត្តសញ្ញាណ និងឯកសារតម្រូវផ្សេងៗទៀតតាមការស្នើសុំពីខេប៊ីប្រាសាក់។

2.2. អតិថិជនយល់ព្រមដាក់ប្រាក់តម្កល់ក្នុងគណនីនូវចំនួនអប្បបរមាទៅតាមប្រភេទគណនីណាមួយស្របទៅតាមលក្ខខណ្ឌដែលបានកំណត់ដោយខេប៊ីប្រាសាក់។

2.3. សម្រាប់ការបើកគណនីប្រាក់បញ្ញើសន្សំ តាមរយៈ **កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល** អតិថិជនមិនតម្រូវឱ្យបំពេញពាក្យស្នើសុំ តែអតិថិជនត្រូវគោរពតាមលក្ខខណ្ឌលម្អិតបន្ថែមផ្សេងទៀតដែលមានបង្ហាញនៅក្នុងកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ឬ មធ្យោបាយអេឡិចត្រូនិកណាមួយដែលទទួលស្គាល់ដោយខេប៊ីប្រាសាក់មុននឹងសម្រេចបើកគណនីនីមួយៗនោះ។

3. គណនីរួម

3.1. គណនីរួម គឺជាគណនីឯកត្តជនដែលមានសមាជិករួមគណនីចាប់ពី ០២នាក់ ឡើងទៅ។

3.2. សមាជិករួមគណនីនីមួយៗ គឺត្រូវបានចាត់ទុកថាជាម្ចាស់គណនី ហើយត្រូវចូលរួមទទួលខុសត្រូវទាំងស្រុងចំពោះខេប៊ីប្រាសាក់ នូវរាល់បំណុល និងកាតព្វកិច្ចនានាដែលកើតមានឡើងនៅក្នុងគណនីរួមនោះ។

4. គណនីនីតិបុគ្គល

4.1. គណនីនីតិបុគ្គល គឺជាគណនីដែលបានបើកក្រោមឈ្មោះក្រុមហ៊ុន សហគ្រាសឯកជន សហគ្រាសរដ្ឋ ក្រសួងមន្ទីរ ស្ថាប័នរបស់រដ្ឋាភិបាល អង្គការ សង្គមស៊ីវិល សហគមន៍ គម្រោងអភិវឌ្ឍន៍ជាដើម ដែលបានបង្កើតឡើងដោយស្របច្បាប់។

4.2. ឈ្មោះគណនី ត្រូវកំណត់ឱ្យបានត្រឹមត្រូវ និងពេញលេញទៅតាមឈ្មោះក្រុមហ៊ុនដែលមាននៅលើវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬ ឯកសារផ្លូវច្បាប់ពាក់ព័ន្ធដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

4.3. អ្នកមានសិទ្ធិធ្វើប្រតិបត្តិគណនី គឺត្រូវបានតែងតាំងចេញពីប្រធានក្រុមហ៊ុន ឬ ក្រុមប្រឹក្សាក្រុមហ៊ុន។

5. គណនីគ្មានប្រតិបត្តិការ

5.1. ប្រសិនបើគណនីរបស់អតិថិជនមិនមានប្រតិបត្តិការក្នុងរយៈពេល ៣៦៥ ថ្ងៃ ឡើងទៅ គណនីនោះនឹងត្រូវចាត់ទុកថាជាគណនីគ្មានប្រតិបត្តិការ។

5.2. អតិថិជនយល់ព្រមឱ្យខេប៊ីប្រាសាក់ធ្វើការទូទាត់កម្រៃសេវានៃគណនីគ្មានប្រតិបត្តិការជាប្រចាំខែ ដោយកម្រៃសេវានឹងត្រូវបានទូទាត់ចេញពីគណនីអតិថិជនដោយស្វ័យប្រវត្តិ និងដោយមិនចាំបាច់ស្នើសុំការអនុញ្ញាតពីអតិថិជនឡើយ។

5.3. អតិថិជនយល់ព្រមថា រាល់គណនីគ្មានប្រតិបត្តិការទាំងឡាយណាដែលមានសមតុល្យតូចជាង ឬ ស្មើសូន្យ នឹងត្រូវបានបិទដោយស្វ័យប្រវត្តិដោយខេប៊ីប្រាសាក់ និងដោយពុំតម្រូវឱ្យធ្វើការជូនដំណឹងដល់អតិថិជនជាមុនឡើយ។

5.4. អនុលោមតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ខេប៊ីប្រាសាក់ត្រូវបានតម្រូវឱ្យធ្វើការបញ្ជូនសមតុល្យនៃគណនីរបស់អតិថិជនទាំងឡាយណាដែលមិនមានប្រតិបត្តិការរយៈពេល ១០ឆ្នាំ ជាប់ៗគ្នាទៅធនាគារជាតិ នៃកម្ពុជា ដើម្បីគ្រប់គ្រងបន្ត។

6. ការផ្តល់ព័ត៌មានរបស់អតិថិជន

6.1. នៅពេលស្នើសុំបើកគណនី និង/ឬ ប្រើប្រាស់សេវាកម្មនានាជាមួយខេប៊ីប្រាសាក់ អតិថិជនត្រូវផ្តល់នូវព័ត៌មាន តាមការស្នើសុំរបស់ខេប៊ីប្រាសាក់ និងត្រូវធានាថា រាល់ព័ត៌មានដែលផ្តល់មកខេប៊ីប្រាសាក់ ជាព័ត៌មាន ពិតប្រាកដ ត្រឹមត្រូវ និងថ្មីបំផុត។

6.2. ករណីមានការផ្លាស់ប្តូរព័ត៌មានផ្សេងៗ អតិថិជនត្រូវធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរមកខេប៊ីប្រាសាក់ជាបន្ទាន់។

6.3. អតិថិជនយល់ព្រមឱ្យខេប៊ីប្រាសាក់ផ្តល់ព័ត៌មានរបស់ខ្លួនទៅភាគីទីបីក្នុង ករណីចាំបាច់ណាមួយ ដែលតម្រូវដោយខេប៊ីប្រាសាក់ផ្ទាល់ ឬ តាមការបង្គាប់បញ្ជាពីតុលាការ ឬ អាជ្ញាធរមានសមត្ថកិច្ច។

6.4. អតិថិជនយល់ព្រមចូលរួមសហការ និងផ្តល់ឱ្យខេប៊ីប្រាសាក់នូវឯកសារគាំទ្រនានា ដែលពាក់ព័ន្ធ ដើម្បីឱ្យខេប៊ីប្រាសាក់អាចអនុវត្តការងារបានត្រឹមត្រូវតាមកាតព្វកិច្ចផ្លូវច្បាប់ ប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

7. ការស្នើសុំកែប្រែព័ត៌មាន និងការជូនដំណឹងពីអតិថិជន

7.1. អតិថិជនអាចធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរមកខេប៊ីប្រាសាក់ ដើម្បីធ្វើការកែប្រែ ឬ ធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់ខ្លួនបាន។

7.2. ខេប៊ីប្រាសាក់នឹងមិនទទួលខុសត្រូវចំពោះ រាល់ការខូចខាតទាំងឡាយណាដែលកើតចេញអំពីការផ្លាស់ប្តូរព័ត៌មានផ្សេងៗរបស់អតិថិជនក្នុងករណីដែលអតិថិជនមិនបានជូនដំណឹងមកខេប៊ីប្រាសាក់។

7.3. ការផ្លាស់ប្តូរព័ត៌មានអាចជា ការបន្ថែម ឬ ដកសិទ្ធិអ្នករួមគណនី ការកែប្រែលក្ខខណ្ឌចុះហត្ថលេខា ការផ្លាស់ប្តូរគំរូហត្ថលេខា ការផ្លាស់ប្តូរឯកសារបញ្ជាក់អត្តសញ្ញាណ ការប្តូរលេខទូរស័ព្ទ ការប្តូរអ៊ីម៉ែល ឬ ការកែប្រែព័ត៌មានផ្ទាល់ខ្លួនផ្សេងៗទៀត ដែលខុសអំពីព័ត៌មានដែលអតិថិជនបានផ្តល់មកខេប៊ីប្រាសាក់ នៅពេលស្នើសុំបើកគណនីដំបូង។

8. ការដាក់ប្រាក់បញ្ញើ

8.1. ខេប៊ីប្រាសាក់ យល់ព្រមឱ្យអតិថិជនដាក់ប្រាក់បញ្ញើជាសាច់ប្រាក់សុទ្ធ ឬ មូលប្បទានប័ត្រ ឬ មូលប្បទានប័ត្រធនាគារិក ឬ ផ្ទេរតាមគណនី ឬ ទូទាត់តាមរយៈការស្តេនខេអេចឃ្យូអរកូត ឬ តាមមធ្យោបាយផ្សេងៗទៀតដែលត្រូវបានអនុញ្ញាតដោយខេប៊ីប្រាសាក់។

8.2. អតិថិជនអាចដាក់ប្រាក់តាមបញ្ជរបេឡា ម៉ាស៊ីនឆូតកាត ម៉ាស៊ីនដាក់ប្រាក់ និងមធ្យោបាយផ្សេងៗទៀតដែលខេប៊ីប្រាសាក់នឹងដាក់ឱ្យប្រើប្រាស់ទៅតាមស្ថានភាពជាក់ស្តែងនាពេលអនាគត។

8.3. ករណីខេប៊ីប្រាសាក់ទទួលបានក្រដាសប្រាក់ក្លែងក្លាយ ឬ ចាស់ ប្រឡាក់ រហែក ឬ ខូចទ្រង់ទ្រាយ តាមរយៈការដាក់ប្រាក់តាមម៉ាស៊ីនដាក់ប្រាក់ នោះខេប៊ីប្រាសាក់រក្សាសិទ្ធិក្នុងការមិនទូទាត់ជូនអតិថិជន ឬ ដកហូត ឬ ទំនាក់ទំនងទៅកាន់អតិថិជនដើម្បីឱ្យមកធ្វើការផ្លាស់ប្តូរក្រដាសប្រាក់ថ្មី ឬ ផ្តល់ជូននូវសេវាកាត់ទឹក។ ខេប៊ីប្រាសាក់រក្សាសិទ្ធិក្នុងការបង្ខាំងទឹកប្រាក់ដែលមានបញ្ហា រហូតដល់អតិថិជនអញ្ជើញ មកដោះស្រាយ ឬ ធ្វើការទូទាត់ទឹកប្រាក់ត្រលប់ ឬ កាត់ទឹក ដោយស្វ័យប្រវត្តិ ករណីអតិថិជនមិនបានអញ្ជើញមកដោះស្រាយបញ្ហាតាមការស្នើសុំពីខេប៊ីប្រាសាក់។

8.4. ខេប៊ីប្រាសាក់ក៏អាចធ្វើការបដិសេធ មិនទទួលយកប្រាក់បញ្ញើពីអតិថិជន ករណីខេប៊ីប្រាសាក់មានការសង្ស័យចំពោះប្រភពដើមនៃប្រាក់បញ្ញើនោះ។

8.5. អតិថិជនយល់ព្រមបង់កម្រៃសេវាលើការដាក់ប្រាក់ឆ្លងសាខា (ប្រសិនបើមាន) ទៅតាមគោលការណ៍ដែលបានកំណត់ដោយខេប៊ីប្រាសាក់។

9. ការដក ឬ ផ្ទេរប្រាក់បញ្ញើ

9.1. អតិថិជនអាចធ្វើប្រតិបត្តិការដកជាសាច់ប្រាក់សុទ្ធ ឬ មូលប្បទានប័ត្រ ឬ មូលប្បទានប័ត្រធនាគារិក ឬ ផ្ទេរប្រាក់ ឬ ដកប្រាក់តាមប័ណ្ណ ឬ ប័ណ្ណឥណពន្ធ ចេញពីគណនីរបស់ខ្លួនដែលមានជាមួយខេប៊ីប្រាសាក់។ សម្រាប់ការដកជាសាច់ប្រាក់ ឬ ផ្ទេរប្រាក់ នៅតាមបញ្ជរបេឡា អតិថិជនត្រូវឱ្យធ្វើការបំពេញ ប័ណ្ណដកប្រាក់បញ្ញើ ឬ ប័ណ្ណផ្ទេរប្រាក់បញ្ញើ ឱ្យបានត្រឹមត្រូវ។

9.2. ការដក ឬ ផ្ទេរប្រាក់ ឬ ទូទាត់តាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល និង/ឬ ប័ណ្ណ និង/ឬ ប័ណ្ណឥណពន្ធ ឬ មធ្យោបាយផ្សេងទៀត ត្រូវបានអនុញ្ញាត ករណីអតិថិជនបានស្នើសុំប្រើប្រាស់ដោយគោរពទៅតាមលក្ខខណ្ឌជាក់លាក់នៃសេវានីមួយៗនោះ។

9.3. អតិថិជនអាចស្នើសុំដក ឬ ផ្ទេរប្រាក់ខុសពីរូបិយប័ណ្ណគណនីបាន ដោយយោងទៅតាមអត្រាប្តូរប្រាក់ស្តង់ដាដែលកំណត់ដោយខេប៊ីប្រាសាក់នៅពេលស្នើសុំធ្វើប្រតិបត្តិការនោះ។

9.4. អតិថិជនយល់ព្រមបង់កម្រៃសេវាលើប្រតិបត្តិការដក ឬ ផ្ទេរឆ្លងសាខា ទៅតាមកម្រៃសេវាស្តង់ដា ដែលបានកំណត់ដោយខេប៊ីប្រាសាក់ ដែលអាចស្វែងរកបាននៅតាមសាខាខេប៊ីប្រាសាក់ ឬ វេបសាយត៍ផ្លូវការរបស់ខេប៊ីប្រាសាក់ www.kbprasacbank.com.kh ។

9.5. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការបដិសេធលើប្រតិបត្តិការដកប្រាក់ ឬ ផ្ទេរប្រាក់ពីអតិថិជន ក្នុងករណីដែលអតិថិជនមិនបានបំពេញពាក្យស្នើសុំដក ឬ ផ្ទេរប្រាក់ឱ្យបានត្រឹមត្រូវ ឬ គណនីនោះត្រូវបានបង្ខាំង ឬ បង្កក ដោយយោងតាមការបង្គាប់បញ្ជាពីស្ថាប័នតុលាការ ធនាគារជាតិនៃកម្ពុជា ឬ អាជ្ញាធរមានសមត្ថកិច្ច។ល។

9.6. ក្នុងករណីអតិថិជនទទួលមរណភាព អតិថិជនយល់ព្រម និងអនុញ្ញាតឱ្យខេប៊ីប្រាសាក់ប្រើឆន្ទានុសិទ្ធិក្នុងការបើកបង្ហាញព័ត៌មានគណនី ដកប្រាក់ ឬ មិនដកប្រាក់ ចេញពីគណនីរបស់អតិថិជន ជូនទៅសន្តតិជន ដែលអាចជា កូនបង្កើត និង/ឬ សហព័ទ្ធ និង/ឬ ឪពុកម្តាយបង្កើត របស់អតិថិជន។ ការដកប្រាក់អាចធ្វើទៅបានដោយ យោងតាមគោលការណ៍របស់ខេប៊ីប្រាសាក់ ឬ ដីកាសម្រេចពីតុលាការ។

10. ឥណទានវិបារូបន៍ (ការដកប្រាក់ដែលធ្វើឱ្យសមតុល្យក្រោមសូន្យ)

10.1. អតិថិជនត្រូវរក្សាសមតុល្យគណនីរបស់ខ្លួនឱ្យធំជាងសូន្យគ្រប់ពេល ឬ ត្រឹមសមតុល្យអប្បបរមា តាមការកំណត់របស់ខេប៊ីប្រាសាក់ លើកលែងករណីដែលខេប៊ីប្រាសាក់ផ្តល់ឱ្យអតិថិជននូវសេវាឥណទានវិបារូបរ៍ (ការដកប្រាក់ដែលធ្វើឱ្យសមតុល្យគណនីក្រោមសូន្យ)។

10.2. ការប្រាក់នឹងគិតចំពោះការដកប្រាក់ក្រោមសូន្យ ដោយគណនាតាមសមតុល្យដែលតូចជាងសូន្យប្រចាំថ្ងៃ គុណនឹងអត្រាជាក់ស្តែងដែលបានកំណត់ដោយខេប៊ីប្រាសាក់នាពេលនោះ។ ការប្រាក់នឹងបញ្ចូលក្នុងខែនីមួយៗ ហើយត្រូវបានបូកបញ្ចូលទៅជាប្រាក់ដើមសម្រាប់គោលបំណងនៃការគណនាការប្រាក់នៅខែបន្ទាប់។

10.3. ខេប៊ីប្រាសាក់ អាចទាមទារឱ្យអតិថិជនសងត្រលប់មកវិញបានគ្រប់ពេល សម្រាប់គណនីដែលមានសមតុល្យក្រោមសូន្យ។

11. ការប្រើប្រាស់មូលប្បទានប័ត្រ

11.1. សូមរក្សាទុកសៀវភៅមូលប្បទានប័ត្រ នៅកន្លែងដែលមានសុវត្ថិភាព និងត្រូវជូនដំណឹងមកធនាគារជាបន្ទាន់ករណីបាត់ ឬ ត្រូវបានលួច។

11.2. ត្រូវមានសមតុល្យសាច់ប្រាក់គ្រប់គ្រាន់ក្នុងគណនី រាល់ពេលចេញផ្សាយមូលប្បទានប័ត្រ។ ការចេញផ្សាយមូលប្បទានប័ត្រ ដែលមិនមានសមតុល្យសាច់ប្រាក់គ្រប់គ្រាន់ គឺជាបទល្មើសព្រហ្មទណ្ឌ។

11.3. ព័ត៌មានដែលសរសេរដោយដៃ ត្រូវតែច្បាស់ និងអានបាន ព្រមទាំងត្រូវសរសេរដោយប្រើទឹកបិកពណ៌ខ្មៅ ឬ ពណ៌ខៀវចាស់ដែលមិនរលុប ជៀសវាងការប្រើទឹកបិកដែលមានលក្ខណៈចាំងពន្លឺ ឬ អាចលុបបាន ឬ ខ្មៅដៃជាដើម។

11.4. សូមកុំចុះហត្ថលេខាលើមូលប្បទានប័ត្រទុកមុន ដោយមិនទាន់ប្រើប្រាស់។

11.5. ទាំងផ្នែខាងមុខ និងផ្នែខាងក្រោយនៃផ្នែលាតសម្រាប់ធនាគារ មិនត្រូវមានការសរសេរ ឬ កាត់ ឬ ហែក ឬ បិទ ឬ កិប ឬ ប្រឡាក់ជាតិគីមីផ្សេងៗ ដែលនាំឱ្យរំខានដល់ការអានរបស់ម៉ាស៊ីនឡើយ។

11.6. មិនត្រូវកោស ឬ លុបតួលេខ និងសញ្ញាពិសេសនៅលើបន្ទាត់លេខកូដនៅក្នុងផ្នែលាតឡើយ។

11.7. មិនត្រូវបត់ និងធ្វើឱ្យរហែកមូលប្បទានប័ត្រ ជាពិសេសនៅផ្នែកសម្រាប់បន្ទាត់លេខកូដ។

11.8. ការប្រើប្រាស់ផ្នែកខាងខ្នងនៃមូលប្បទានប័ត្រ ត្រូវបានអនុញ្ញាតតែចំពោះផ្នែក សម្រាប់ធនាគារ និងអតិថិជន តែប៉ុណ្ណោះ។

11.9. ដើម្បីកែប្រែព័ត៌មានណាមួយលើមូលប្បទានប័ត្រ ម្ចាស់មូលប្បទានប័ត្រត្រូវគូសឆូតចោលព័ត៌មានដែលចង់កែតម្រូវ ហើយចុះហត្ថលេខារបស់ខ្លួននៅពីលើផ្នែកដែលត្រូវបានកែតម្រូវនោះ ជៀសវាងការប្រើទឹកលុប ឬ កោសលុបខុសទ្រង់ទ្រាយដើម។

11.10. មូលប្បទានប័ត្រអាចទូទាត់បានដោយមិនគិតពីថ្ងៃចេញផ្សាយ។ សុពលភាពសម្រាប់ប្រើប្រាស់មូលប្បទានប័ត្រមានរយៈពេល 06 ខែ គិតចាប់ពីថ្ងៃចេញមូលប្បទានប័ត្រ។

11.11. ធនាគារ រក្សាសិទ្ធិក្នុងការបិទ/ផ្អាកគណនី ប្រសិនបើម្ចាស់គណនីចេញផ្សាយមូលប្បទានប័ត្រ ដោយគ្មានសមតុល្យគ្រប់គ្រាន់ ឬ ប្រើប្រាស់មូលប្បទានប័ត្រក្នុងគោលបំណងផ្ទុយពីច្បាប់។

11.12. រាល់មូលប្បទានប័ត្របញ្ជូនត្រលប់ ឬ បង្វិល ដោយសារគ្មាន ឬ មិនមានទឹកប្រាក់គ្រប់គ្រាន់ក្នុងគណនី នឹងត្រូវគិតកម្រៃដោយយោងតាមលក្ខខណ្ឌរបស់ធនាគារ។ អតិថិជនយល់ព្រមឱ្យធនាគារធ្វើការទូទាត់កម្រៃសេវាចេញពីគណនីរបស់អតិថិជនដោយស្វ័យប្រវត្តិ។

11.13. ធនាគារនឹងបញ្ចូលព័ត៌មានពាក់ព័ន្ធនឹងការបង្វិលមូលប្បទានប័ត្រត្រលប់ទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន របស់ក្រុមហ៊ុនក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី(ស៊ីប៊ីស៊ី) ផ្អែកតាមប្រកាសរបស់ធនាគារជាតិ នៃ កម្ពុជា។

11.14. ធនាគារ នឹងមិនអនុញ្ញាតឱ្យបិទគណនី តាមការស្នើសុំរបស់អតិថិជននោះឡើយ ករណីដែលអតិថិជនបានចេញផ្សាយមូលប្បទានប័ត្រ ហើយមិនទាន់បានទូទាត់ឱ្យបានរួចរាល់មុនពេលស្នើសុំបិទគណនី។

12. សេវាធនាគារអន្តរជាតិ

12.1. ខេប៊ីប្រាសាក់ ផ្តល់ជូនសេវាធនាគារអន្តរជាតិ រួមមាន សេវាផ្ទេរប្រាក់អន្តរជាតិ សេវាហិរញ្ញប្បទានពាណិជ្ជកម្ម និងសេវាកម្មពាក់ពន្ធ័ផ្សេងៗទៀត។

12.2. អតិថិជនអាចស្នើសុំប្រើប្រាស់ សេវាធនាគារអន្តរជាតិ នៅតាមសាខាណាមួយរបស់ខេប៊ីប្រាសាក់ ឬ តាមបណ្តាញឌីជីថលរបស់ខេប៊ីប្រាសាក់ ឬ មធ្យោបាយផ្សេងៗទៀតដែលត្រូវបានអនុញ្ញាតដោយខេប៊ីប្រាសាក់។

12.3. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការកំណត់នូវទំហំនៃការធ្វើប្រតិបត្តិការប្រចាំថ្ងៃ និង/ឬ ទំហំក្នុងមួយប្រតិបត្តិការ លើការប្រើប្រាស់សេវាធនាគារអន្តរជាតិ ដោយយោងទៅតាមលក្ខខណ្ឌ និងប្រភេទប្រតិបត្តិការជាក់លាក់នៃសេវាកម្មនីមួយៗ។

12.4. អតិថិជនត្រូវធានា និងទទួលខុសត្រូវក្នុងការផ្តល់ព័ត៌មាន និងឯកសារដែលត្រឹមត្រូវ និងច្បាស់លាស់ទៅតាមការស្នើសុំពីខេប៊ីប្រាសាក់ និងទទួលខុសត្រូវស្របទៅតាមរាល់វិធានច្បាប់របស់ ព្រះរាជាណាចក្រកម្ពុជា និងច្បាប់អន្តរជាតិ លើការស្នើសុំធ្វើប្រតិបត្តិការសេវាធនាគារអន្តរជាតិ និងធានាថារាល់សកម្មភាព គឺធ្វើឡើងដោយផ្ទាល់សម្រាប់ខ្លួនឯង។

12.5. អតិថិជនត្រូវយល់ព្រមដោយគ្មានលក្ខខណ្ឌក្នុងការផ្តល់សំណង ទូទាត់ត្រលប់ និងទូទាត់សងត្រលប់ទៅ ខេប៊ីប្រាសាក់ លើកម្រៃជើងសារ ការទាមទារ ការតម្រូវ ការខាតបង់ ការចំណាយ បំណុល កាតព្វកិច្ច និងសំណងផ្សេងៗដែលកើតឡើងពីប្រតិបត្តិការសេវាធនាគារអន្តរជាតិរបស់ខ្លួន។

12.6. ខេប៊ីប្រាសាក់ អាចបដិសេធមិនធ្វើ ឬ ពន្យារពេលលើការធ្វើប្រតិបត្តិការណាមួយ ក្នុងករណីដែល ខេប៊ីប្រាសាក់ ជឿជាក់ថាប្រតិបត្តិការនោះ ពាក់ព័ន្ធទៅនឹងទំនិញ/សេវាកម្ម ឬ សកម្មភាព មិនស្របទៅនឹងច្បាប់ជាតិ ឬ ច្បាប់អន្តរជាតិ និង/ឬ ប្រតិបត្តិការជាប់ពាក់ព័ន្ធដោយផ្ទាល់ ឬ ដោយប្រយោលជាមួយបុគ្គល ឬ អង្គភាព ឬ ប្រទេសណាមួយដែលខុសច្បាប់ ឬ ត្រូវបានដាក់ទណ្ឌកម្ម។

13. ការបញ្ជាទូទាត់

13.1. អតិថិជនអាចធ្វើការបញ្ជាទូទាត់ជាលាយលក្ខណ៍អក្សរមកខេប៊ីប្រាសាក់ ឬ តាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ឬ សេវាខេប៊ីប្រាសាក់ខបភើរេត ឬ ប័ណ្ណ ឬ ប័ណ្ណឥណពន្ធ ឬ មធ្យោបាយផ្សេងៗដែលផ្តល់ដោយខេប៊ីប្រាសាក់ ដោយអតិថិជនត្រូវផ្តល់ព័ត៌មានរបស់អ្នកទទួលផលឱ្យបានគ្រប់គ្រាន់ និងត្រឹមត្រូវ ។

13.2. ខេប៊ីប្រាសាក់ នឹងមិនទទួលខុសត្រូវ ចំពោះការបាត់បង់ទាំងឡាយណាដែលបង្កឡើងដោយការផ្តល់ព័ត៌មានមិនត្រឹមត្រូវ និង/ឬ មិនគ្រប់គ្រាន់របស់អតិថិជននោះទេ។

14. ការបង្ខាំងគណនី ឬ សមតុល្យគណនី

ខេប៊ីប្រាសាក់នឹងធ្វើការបង្ខាំងគណនី ឬ សមតុល្យគណនីរបស់អតិថិជនក្នុងករណីដូចខាងក្រោម៖

- មានការស្នើសុំជាលាយលក្ខណ៍អក្សរពីអតិថិជន
- មានការស្នើសុំពីអតិថិជនតាមរយៈទូរស័ព្ទមកមន្ត្រីទំនាក់ទំនងអតិថិជន (Call Center) រួមទាំងអតិថិជនខេប៊ីប្រាសាក់ ឬ អតិថិជននៃធនាគារផ្សេង ក្នុងករណីអតិថិជនធ្វើប្រតិបត្តិការផ្ទេរ ឬ ដាក់ប្រាក់ខុសលេខគណនី
- តាមសេចក្តីបង្គាប់បញ្ជារបស់ស្ថាប័នតុលាការ ធនាគារជាតិនៃកម្ពុជា ឬ អាជ្ញាធរមានសមត្ថកិច្ចជាដើម។

15. ការដោះបង្ខាំងគណនី ឬ សមតុល្យគណនី

ខេប៊ីប្រាសាក់នឹងធ្វើការដោះបង្ខាំងគណនី ឬ សមតុល្យគណនីដែលត្រូវបានបង្ខាំងក្នុងករណីណាមួយខាងក្រោម៖

- មានការស្នើសុំជាលាយលក្ខណ៍អក្សរពីអតិថិជន (ក្នុងករណីអតិថិជនស្នើសុំបង្ខាំងគណនី) ឬ
- តាមនីតិវិធីនៃការដោះស្រាយបណ្តឹងរបស់អតិថិជនលើការផ្ទេរ/ដាក់ប្រាក់ខុសលេខគណនី ឬ
- តាមសេចក្តីបង្គាប់បញ្ជារបស់ស្ថាប័នតុលាការ ធនាគារជាតិនៃកម្ពុជា ឬ អាជ្ញាធរមានសមត្ថកិច្ចជាដើម។

16. កម្រៃសេវាកម្ម

16.1. អតិថិជន មានកាតព្វកិច្ចបង់កម្រៃសេវាកម្មផ្សេងៗដូចមានចែងនៅក្នុងតារាងតម្លៃសេវាស្តង់ដារបស់ខេប៊ីប្រាសាក់ ទៅតាមប្រភេទ និងលក្ខខណ្ឌនីមួយៗពាក់ព័ន្ធនឹងការប្រើប្រាស់ផលិតផល និងសេវាកម្មផ្សេងៗរបស់ខេប៊ីប្រាសាក់។

16.2. ខេប៊ីប្រាសាក់នឹងកាត់ប្រាក់កម្រៃខាងលើ ចេញពីគណនីដោយមិនចាំបាច់សុំការអនុញ្ញាតពីអតិថិជនឡើយរួមមាន ប្រាក់ពិន័យ ការប្រាក់ ប្រាក់ពន្ធ ប្រាក់កម្រៃជើងសា និងកម្រៃសេវាកម្មនានា ដែលអតិថិជនជំពាក់ ឬ មិនទាន់បានបង់មកឱ្យខេប៊ីប្រាសាក់។

16.3. ចំពោះតារាងតម្លៃសេវាកម្មស្តង់ដានេះ អតិថិជនអាចស្វែងរកបាននៅគ្រប់ការិយាល័យ និង/ឬ វេបសាយត៍របស់ខេប៊ីប្រាសាក់ www.kbprasacbank.com.kh ឬ ទាក់ទងមកកាន់មន្ត្រីបម្រើសេវាអតិថិជន តាមរយៈទូរស័ព្ទលេខ ០២៣/០៨៦ ៩៩៩ ៩១១។

17. អត្រាការប្រាក់លើប្រាក់បញ្ញើ

17.1. ខេប៊ីប្រាសាក់នឹងគណនា និងទូទាត់ការប្រាក់ជូនទៅអតិថិជនដោយយោងតាមអត្រាការប្រាក់ស្តង់ដាទៅតាមប្រភេទគណនីប្រាក់បញ្ញើសន្សំនីមួយៗ ដែលបានកំណត់ដោយខេប៊ីប្រាសាក់។

17.2. ការប្រាក់ត្រូវបានគណនាដោយផ្អែកទៅលើសមតុល្យប្រចាំថ្ងៃ ផ្អែកលើរយៈពេល ៣៦៥ថ្ងៃ ក្នុងមួយឆ្នាំ និងផ្អែកតាមប្រភេទរូបិយប័ណ្ណនៃគណនីនោះ។

17.3. ការប្រាក់នឹងត្រូវបញ្ចូលទៅក្នុងគណនីជាប្រចាំខែ ឬ ប្រចាំឆ្នាំ ឬ ពេលគណនីដល់កាលកំណត់ ឬ ពេលបិទគណនី ដោយអាស្រ័យទៅលើប្រភេទគណនីនីមួយៗដែលអតិថិជនបានស្នើសុំបើក។

18. ការកែប្រែកម្រៃសេវា អត្រាការប្រាក់ ទំហំកំណត់ លក្ខខណ្ឌផ្សេងៗ និងការជូនដំណឹងទៅអតិថិជន

18.1. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការកែប្រែកម្រៃសេវា អត្រាការប្រាក់ ទំហំកំណត់ និង/ឬ លក្ខខណ្ឌផ្សេងៗ ដែលត្រូវអនុវត្តចំពោះការប្រើប្រាស់គណនី និង/ឬ សេវាណាមួយ របស់អតិថិជន ដោយខេប៊ីប្រាសាក់នឹងធ្វើការជូនដំណឹងទៅអតិថិជនឱ្យបានត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវនៃច្បាប់។

18.2. ក្នុងរយៈពេលនៃការជូនដំណឹង ករណីមិនមានការតវ៉ាពីសំណាក់អតិថិជន ត្រូវសន្មតថាអតិថិជនបានយល់ព្រម និងទទួលយកការកែប្រែខាងលើមកអនុវត្តភ្លាមៗបន្ទាប់ពីការកែប្រែចូលជាធរមានដែលត្រូវបានផ្សព្វផ្សាយ តាមរយៈមធ្យោបាយណាមួយខាងក្រោម៖

(1) តាមរយៈសាខារបស់ខេប៊ីប្រាសាក់ និង/ឬ

(2) តាមរយៈវេបសាយត៍ និង/ឬ បណ្តាញទំនាក់ទំនងសង្គមផ្លូវការរបស់ខេប៊ីប្រាសាក់ និង/ឬ

(3) ការផ្ញើសារ និង/ឬ អ៊ីម៉ែលទៅកាន់អតិថិជន

(4) តាមរយៈការផ្សព្វផ្សាយនៅលើទំព័រការសែត ទស្សនាវដ្តី កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល សេវាខេប៊ីប្រាសាក់ឧបភោគបរិភោគ ឬ មធ្យោបាយផ្សេងៗ ដែលខេប៊ីប្រាសាក់បានជ្រើសរើស។ល។

18.3. អតិថិជនត្រូវបានសន្មតថាបានទទួលការជូនដំណឹងស្តីពីការកែប្រែខាងលើភ្លាមៗ បន្ទាប់ពីខេប៊ីប្រាសាក់ បានធ្វើការចុះផ្សាយពីការកែប្រែព័ត៌មាននានារបស់ខ្លួន តាមរយៈមធ្យោបាយណាមួយក្នុងចំណោមមធ្យោបាយខាងលើ។

19. ពន្ធកាត់ទុក (ពន្ធលើការប្រាក់)

19.1. អតិថិជន (ម្ចាស់គណនី) បានទទួលស្គាល់ថា ពន្ធកាត់ទុកលើការប្រាក់ដែលទទួលបានពីការដាក់ប្រាក់បញ្ញើជាមួយខេប៊ីប្រាសាក់ជាបន្ទុករបស់ខ្លួន។

19.2. អតិថិជនយល់ព្រមឱ្យខេប៊ីប្រាសាក់ធ្វើការកាត់ប្រាក់ពន្ធដែលត្រូវបង់ចេញពីគណនីរបស់អតិថិជនដោយផ្ទាល់ និងមិនចាំបាច់មានការយល់ព្រមពីអតិថិជនឡើយ។

19.3. ការកាត់ប្រាក់ពន្ធនេះនឹងត្រូវធ្វើឡើងរៀងរាល់ពេលដែលខេប៊ីប្រាសាក់ធ្វើការបញ្ចូលការប្រាក់ទៅក្នុងគណនីរបស់អតិថិជនទៅតាមអត្រាពន្ធជាក់ស្តែងដែលត្រូវបានកំណត់ដោយច្បាប់ ឬ លិខិតបទដ្ឋានគតិយុត្តិជាធរមាន។

20. ទំហំទឹកប្រាក់បញ្ញើ

20.1. ទំហំទឹកប្រាក់អតិបរមានៃការដាក់ប្រាក់បញ្ញើសន្សំសម្រាប់អតិថិជនម្នាក់ គឺមិនកំណត់។

20.2. ទំហំទឹកប្រាក់សម្រាប់ការធ្វើប្រតិបត្តិការ គឺត្រូវបានកំណត់ទៅតាមប្រភេទប្រតិបត្តិការនីមួយៗ ដែលអតិថិជនអាចស្វែងរកបាននៅក្នុងលក្ខខណ្ឌជាក់លាក់នៃសេវានីមួយៗ និង/ឬ តាមសាខាខេប៊ីប្រាសាក់ និង/ឬ វេបសាយត៍ផ្លូវការរបស់ខេប៊ីប្រាសាក់។

21. ប្រភេទរូបិយប័ណ្ណ

21.1. អតិថិជនអាចបើកគណនី ឬ ធ្វើប្រតិបត្តិការ ជាមួយរូបិយប័ណ្ណដូចខាងក្រោម៖

- ខ្មែររៀល (KHR) និង
- ដុល្លារអាមេរិក (USD)

21.2. អតិថិជនអាចធ្វើប្រតិបត្តិការឆ្លងរូបិយប័ណ្ណបាន ដោយត្រូវយោងទៅតាមអត្រាប្តូរប្រាក់ជាក់ស្តែង របស់ខេប៊ីប្រាសាក់នៅថ្ងៃធ្វើប្រតិបត្តិការនោះ។

22. អត្រាប្តូរប្រាក់

22.1. អតិថិជនអាចស្វែងរកអត្រាប្តូរប្រាក់ប្រចាំថ្ងៃរបស់ខេប៊ីប្រាសាក់ ដែលមានបិទផ្សាយនៅតាមបណ្តាសាខាខេប៊ីប្រាសាក់ ឬ វេបសាយត៍ផ្លូវការរបស់ខេប៊ីប្រាសាក់ ឬ កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ឬ សេវាខេប៊ីប្រាសាក់ខបភើរេត ឬ តាមមធ្យោបាយផ្សេងៗដែលផ្តល់ដោយខេប៊ីប្រាសាក់។

22.2. រាល់ពេលធ្វើប្រតិបត្តិការលើគណនី ឬ ប្រើប្រាស់សេវាកម្មណាមួយជាមួយខេប៊ីប្រាសាក់ដោយឆ្លងរូបិយប័ណ្ណ អតិថិជនយល់ព្រមទទួលយកអត្រាប្តូរប្រាក់ស្តង់ដា ដែលខេប៊ីប្រាសាក់បានកំណត់នៅក្នុងពេលដែលធ្វើប្រតិបត្តិការនោះ។

23. ការស្នើសុំបិទគណនី

23.1. រាល់ការស្នើសុំបិទគណនី ត្រូវធ្វើឡើងដោយផ្ទាល់ពីអតិថិជនជាម្ចាស់គណនី ឬ តាមការកំណត់ដោយច្បាប់ ឬ អាជ្ញាធរមានសមត្ថកិច្ច។

23.2. ចំពោះការស្នើសុំបិទគណនីដែលមានកាលកំណត់ មុនកាលកំណត់ អតិថិជនយល់ព្រមចំពោះការខាតបង់ការប្រាក់ដែលនឹងត្រូវទទួលបាន ហើយខេប៊ីប្រាសាក់រក្សាសិទ្ធិគ្រប់បែបយ៉ាងក្នុងការកំណត់ អត្រាការប្រាក់ ដែលត្រូវផ្តល់ជូនអតិថិជន។

24. ឯកសារគណនី (សៀវភៅគណនីសន្សំ/វិញ្ញាបនបត្រប្រាក់បញ្ញើមានកាលកំណត់/ប័ណ្ណព័ត៌មានគណនី)

24.1. អតិថិជនអាចស្នើសុំ សៀវភៅគណនីសន្សំ ឬ ប័ណ្ណព័ត៌មានគណនីសម្រាប់ប្រភេទគណនីបញ្ញើសន្សំ និង/ឬ វិញ្ញាបនបត្រដាក់ប្រាក់បញ្ញើសន្សំ សម្រាប់ប្រភេទគណនីបញ្ញើមានកាលកំណត់ ហើយរាល់កម្រៃសេវាត្រូវបានកំណត់ដោយខេប៊ីប្រាសាក់។

24.2. អតិថិជនត្រូវត្រួតពិនិត្យរបាយការណ៍គណនីរបស់ខ្លួនដែលបានបង្ហាញនៅក្នុងសៀវភៅគណនីសន្សំ និង /ឬ របាយការណ៍គណនី នឹងត្រូវជូនដំណឹងមកខេប៊ីប្រាសាក់ភ្លាមៗក្នុងអំឡុងពេល ១៤ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបោះពុម្ពទិន្នន័យ ក្នុងករណីរកឃើញនូវភាពមិនប្រក្រតី មិនត្រឹមត្រូវ ឬ មានការកោសលុបផ្សេងៗ។

24.3. ករណីមិនមានការជូនដំណឹងពីអតិថិជន របាយការណ៍សមតុល្យនោះនឹងត្រូវបានចាត់ទុកថាត្រឹមត្រូវ ហើយអតិថិជនមិនមានសិទ្ធិជំទាស់ ឬ ប្តឹងទាមទារសំណងពីខេប៊ីប្រាសាក់ឡើយ។

24.4. ខេប៊ីប្រាសាក់មានសិទ្ធិក្នុងការកែតម្រូវទិន្នន័យដែលខុសនៅក្នុងសៀវភៅគណនីសន្សំ ហើយទិន្នន័យដែលបានកែតម្រូវនោះនឹងមានសុពលភាពសម្រាប់អតិថិជន។

24.5. នៅពេលបាត់សៀវភៅគណនីសន្សំ និង/ឬ វិញ្ញាបនបត្រប្រាក់បញ្ញើមានកាលកំណត់ អតិថិជនត្រូវជូនដំណឹងមកខេប៊ីប្រាសាក់ជាលាយលក្ខណ៍អក្សរជាបន្ទាន់ ដោយបញ្ជាក់ឱ្យបានច្បាស់ពី កាលបរិច្ឆេទ និងទីកន្លែងដែលបាត់។

24.6. អតិថិជននឹងត្រូវបានផ្តល់នូវសៀវភៅគណនីសន្សំ ឬ វិញ្ញាបនបត្រប្រាក់បញ្ញើមានកាលកំណត់ថ្មី ជំនួសឯកសារគណនីដែលបានបាត់ ប៉ុន្តែត្រូវយល់ព្រមបង់កម្រៃសេវាទៅតាមកម្រៃសេវាស្តង់ដារបស់ខេប៊ីប្រាសាក់។

24.7. ខេប៊ីប្រាសាក់មិនទទួលខុសត្រូវចំពោះអតិថិជន ឬ ភាគីទីបីណាមួយ ប្រសិនបើមានប្រតិបត្តិការគណនីណាមួយ កើតឡើងទាក់ទងទៅនឹងគណនីនោះ មុនពេលអតិថិជនជូនដំណឹងមកខេប៊ីប្រាសាក់ឡើយ។

25. របាយការណ៍គណនី

25.1. ខេប៊ីប្រាសាក់នឹងផ្តល់របាយការណ៍គណនីទាក់ទងទៅនឹងប្រតិបត្តិការចេញ ឬ ចូលក្នុងគណនីរបស់អតិថិជនទៅតាមការស្នើសុំជាក់ស្តែងពីអតិថិជន។

25.2. អតិថិជនអាចធ្វើការស្នើសុំរបាយការណ៍គណនីនៅតាមបណ្តាសាខាណាមួយរបស់ខេប៊ីប្រាសាក់ ឬ ទាញយកតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ឬ សេវាខេប៊ីប្រាសាក់ខបភើរេត ឬ មធ្យោបាយផ្សេងទៀតផ្តល់ដោយខេប៊ីប្រាសាក់។

25.3. អតិថិជនត្រូវត្រួតពិនិត្យរបាយការណ៍គណនីរបស់ខ្លួនដែលបង្ហាញក្នុងរបាយការណ៍គណនីនោះ និងត្រូវជូនដំណឹងមកខេប៊ីប្រាសាក់ភ្លាមក្នុងអំឡុងពេល ១៤ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបោះពុម្ពទិន្នន័យ ក្នុងករណីឃើញភាពមិនប្រក្រតី ឬ មិនត្រឹមត្រូវ ឬ មានការកោសលុបផ្សេងៗ។

26. សិទ្ធិក្នុងការទូទាត់

26.1. បន្ថែមលើការព្រមព្រៀងផ្សេងៗ ខេប៊ីប្រាសាក់មានសិទ្ធិក្នុងការទូទាត់ទឹកប្រាក់នៅក្នុងគណនី ដើម្បីទូទាត់បំណុលដោយពុំតម្រូវឱ្យធ្វើការជូនដំណឹងដល់អតិថិជនជាមុនឡើយ។ ខេប៊ីប្រាសាក់នឹងធ្វើការទូទាត់ទឹកប្រាក់ចេញពីគណនីនូវចំនួនទឹកប្រាក់ដែលអតិថិជនជំពាក់ខេប៊ីប្រាសាក់ ទោះជាបំណុលរួម ឬ ដាច់ដោយឡែកក៏ដោយ។

26.2. ខេប៊ីប្រាសាក់រក្សាសិទ្ធិក្នុងការកែតម្រូវ ឬ ទូទាត់ចេញពីគណនីអតិថិជន ចំពោះប្រតិបត្តិការដាក់ប្រាក់ ដកប្រាក់ ផ្ទេរប្រាក់ ឬ ការទូទាត់ទាំងឡាយណា ដែលធ្វើឡើងដោយកំហុសបច្ចេកទេស ឬ ការដោះស្រាយបណ្តឹងលើការផ្ទេរ/ដាក់ប្រាក់ខុសលេខគណនី ដោយពុំតម្រូវឱ្យធ្វើការស្នើសុំការអនុញ្ញាតពីអតិថិជនឡើយ។

27. ការរំខានដល់សេវាកម្ម និងប្រធានសក្តិ

27.1. ខេប៊ីប្រាសាក់នឹងមិនទទួលរ៉ាប់រងលើការខាតបង់ទាំងឡាយណា ដែលបណ្តាលមកពីការរអាក់រអួលរបស់ប្រព័ន្ធ ឬ ឧបករណ៍ដំណើរការមិនប្រក្រតីឡើយ។

27.2. ដូចគ្នានេះដែរ ខេប៊ីប្រាសាក់ក៏នឹងមិនទទួលខុសត្រូវចំពោះការខូចខាតទាំងឡាយណា ដែលបណ្តាលមកពីការខកខានមិនបានបំពេញសេវាកម្ម ឬ កាតព្វកិច្ចរបស់ខ្លួនដោយសារករណីប្រធានសក្តិ រួមមាន គ្រោះទឹកជំនន់ ខ្យល់ព្យុះ គ្រោះរាំងស្ងួត ភេរវកម្ម កុប្បកម្ម សង្គ្រាម ឬ ក៏មូលហេតុផ្សេងទៀតដែលហួសពីលទ្ធភាពគ្រប់គ្រងបានរបស់ខេប៊ីប្រាសាក់។

28. ការរក្សាព័ត៌មានអតិថិជនជាការសម្ងាត់

28.1. ខេប៊ីប្រាសាក់នឹងរក្សារាល់ព័ត៌មានទាំងអស់របស់អតិថិជនជាការសម្ងាត់។

28.2. ខេប៊ីប្រាសាក់នឹងមិនបញ្ចេញព័ត៌មានរបស់អតិថិជនទៅកាន់ភាគីទីបី ដោយមិនមានការអនុញ្ញាតពីអតិថិជនឡើយ លើកលែងតែការស្នើសុំនោះតម្រូវដោយច្បាប់ ឬ ធ្វើឡើងដោយស្ថាប័នមានសមត្ថកិច្ច។

28.3. អតិថិជន ធានាអះអាងថា ខ្លួនគោរពទៅតាមគោលការណ៍ សេចក្តីណែនាំនានាលើការប្រើប្រាស់សេវាកម្មរបស់ខេប៊ីប្រាសាក់ ហើយត្រូវយកចិត្តទុកដាក់លើការគ្រប់គ្រង ថែរក្សានូវព័ត៌មានផ្ទាល់ខ្លួន ទ្រព្យសម្បត្តិ និងឯកសារពាក់ព័ន្ធនឹងគណនី និងការប្រើប្រាស់សេវានានារបស់ធនាគារ ដោយមិនត្រូវផ្ទេរ ឬ ផ្តល់ឱ្យទៅបុគ្គលណាម្នាក់នោះឡើយ។ អតិថិជន គឺជាអ្នកទទួលខុសត្រូវដោយផ្ទាល់ លើរាល់ការខូចខាតនានា កើតចេញពីការធ្វេសប្រហែស ការចែករំលែក ការផ្ទេរ ឬ ផ្តល់ឱ្យនូវព័ត៌មានផ្ទាល់ខ្លួន ទ្រព្យសម្បត្តិ និងឯកសារទាំងនោះ។

29. ការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងបទឧក្រិដ្ឋផ្សេងៗ

29.1. ខេប៊ីប្រាសាក់ត្រូវបានតម្រូវឱ្យអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិ ជាធរមាន ពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងបទឧក្រិដ្ឋផ្សេងៗ។

29.2. ខេប៊ីប្រាសាក់អាចចាត់វិធានការនានាតាមឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីគោរពតាមច្បាប់ និងបទប្បញ្ញាតិជាធរមាន។

29.3. អតិថិជនយល់ព្រមជាមួយខេប៊ីប្រាសាក់ថា ខេប៊ីប្រាសាក់អាចនឹងពន្យារពេល ឬ បង្ខាំងទុក ឬ បដិសេធមិនឱ្យដំណើរការនូវប្រតិបត្តិការណាមួយដោយមិនមានការទទួលខុសត្រូវ ប្រសិនបើខេប៊ីប្រាសាក់សង្ស័យថា៖

- ប្រតិបត្តិការដែលបានធ្វើឡើងនោះអាចផ្ទុយនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬ ច្បាប់អន្តរជាតិ
- ប្រតិបត្តិការដែលបានធ្វើឡើងនោះអាចនឹងពាក់ព័ន្ធដោយផ្ទាល់ និង/ឬ ដោយប្រយោលទៅនឹងដំណើរការ ឬ គោលបំណងនៃការប្រព្រឹត្តសកម្មភាពខុសច្បាប់។

30. ច្បាប់អនុវត្ត

30.1. រាល់លក្ខខណ្ឌទាំងឡាយដែលមានចែងនៅក្នុងលក្ខខណ្ឌទូទៅនេះ ត្រូវអនុវត្តឱ្យស្របតាមច្បាប់ គោលការណ៍ និងនីតិវិធីរបស់ខេប៊ីប្រាសាក់។

30.2. ប្រសិនបើលក្ខខណ្ឌណាមួយនៅក្នុងលក្ខខណ្ឌទូទៅនេះ មិនអាចអនុវត្តបាន ឬ គ្មានសុពលភាពស្របតាមផ្លូវច្បាប់ លក្ខខណ្ឌទាំងនោះនឹងអស់សុពលភាពត្រឹមកម្រិតដែលលក្ខខណ្ឌនោះមិនអាចអនុវត្តបាន ឬ អសុពលភាពនៃលក្ខខណ្ឌនោះតែប៉ុណ្ណោះ ចំណែកលក្ខខណ្ឌផ្សេងៗទៀតនៃលក្ខខណ្ឌទូទៅនេះនៅតែបន្តមានសុពលភាពអនុវត្តដដែល។

30.3. រាល់វិវាទដែលកើតចេញពីការបកស្រាយខ្លឹមសារផ្សេងគ្នារវាងអតិថិជន (ម្ចាស់គណនី) និងខេប៊ីប្រាសាក់ គឺត្រូវបកស្រាយដោយអនុលោមទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

30.4. រាល់ផលិតផល និងសេវាកម្មទាំងអស់របស់ខេប៊ីប្រាសាក់ ត្រូវអនុវត្តតាមលក្ខខណ្ឌទូទៅនេះ។ ក្នុងករណីលក្ខខណ្ឌទាំងឡាយណា ដែលមានចែងនៅក្នុងលក្ខខណ្ឌទូទៅនេះផ្ទុយទៅនឹងលក្ខខណ្ឌលម្អិត ឬ លក្ខខណ្ឌជាក់លាក់នៃផលិតផលនីមួយៗ នោះលក្ខខណ្ឌលម្អិត ឬ លក្ខខណ្ឌជាក់លាក់របស់ផលិតផល នោះត្រូវយកជាគោល។

30.5. លក្ខខណ្ឌទូទៅនេះត្រូវបានធ្វើឡើងជាភាសាខ្មែរ និងអង់គ្លេស។ ករណីមានចំណុចណាមួយរវាងអត្ថបទ ទាំងពីរមានន័យមិនស្រប ឬ មិនស៊ីគ្នា នោះអត្ថបទជាភាសាខ្មែរចាត់ទុកជាផ្លូវការ។

ចប់